សម្រាប់ការចេញផ្សាយភ្លាមៗ

គណៈកម្មការទន្លេមេគង្គចេញផ្សាយយុទ្ធសាស្ត្រ ១០ឆ្នាំ និងផែនការ៥ឆ្នាំថ្មី ដើម្បីបង្កើតតុល្យភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេមេគង្គ

ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ – ថ្ងៃនេះ គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) បានចេញផ្សាយនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ រយៈពេល ១០ឆ្នាំថ្មីមួយ (BDS) សម្រាប់ការគ្រប់គ្រងអាងទន្លេមេគង្គ និងផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ (MRC SP) ដើម្បីជួយឲ្យប្រទេសតាមអាងទន្លេមេគង្គ ដោះស្រាយបញ្ហាប្រឈមដែលកើតមាន និងធ្វើឲ្យស្ថានភាពអាងជារួមបានប្រសើរឡើង។

អនុម័តដោយក្រុមប្រឹក្សាថ្នាក់រដ្ឋមន្ត្រីមកពីប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម BDS ២០២១-២០៣០ ផ្តោតលើវិស័យអាទិភាពចំនួន៥។ វិស័យទាំងនេះ រួមមានការធ្វើឲ្យប្រសើរឡើងនូវមុខងារអេកូឡូស៊ីនៃទន្លេមេគង្គសម្រាប់សុខភាពបរិស្ថាន និងសហគមន៍ប្រកបដោយផលិតភាព, ការជំរុញលទ្ធភាពទទួលបាន និងប្រើប្រាស់ធនធានទឹក និងធនធានពាក់ព័ន្ធនានាឲ្យបានកាន់តែប្រសើរសម្រាប់សុខមាលភាពសហគមន៍, ការអភិវឌ្ឍនិរន្តភាពសម្រាប់កំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន, ភាពធន់ទប់ទល់នឹងហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយនានា, និងការពង្រឹងនូវកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ដោយផ្អែកលើទស្សនវិស័យសម្រាប់អាងទន្លេទាំងមូល។

“យុទ្ធសាស្ត្រនេះ ស្របទៅនឹងអាទិភាពរបស់រដ្ឋាភិបាលតាមដងទន្លេមេគង្គ និងតម្រូវការក្នុងការសម្រេចឲ្យបាននូវអាងទន្លេមេគង្គមួយ ដែលកាន់តែធន់ និងមុាំមួនជាងមុន តាមរយៈការរៀបចំផែនការបែបបរិសកម្ម និងការគ្រប់គ្រងដោយសម្របសម្រួល ដែលជាលទ្ធផល វាធានាឲ្យមានតុល្យភាពរវាងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងការគាំពារផ្នែកបរិស្ថាន”។ នេះជាប្រសាសន៍របស់បណ្ឌិត អាន ពេជ្រហត្ថដា នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC ដែលបានថ្លែងឡើងនៅឯពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៃ BDS និង MRC SP កាលពីថ្ងៃចន្ទនេះ។ ព្រឹត្តការណ៍នេះ ក៏បានរំលឹកដល់ទិវាមេគង្គ ដែលប្រទេសជាសមាជិករបស់ MRC បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទន្លេមេគង្គ កាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៥ផងដែរ។

BDS ថ្មីនេះ គឺយោងលើការវាយតម្លៃថ្មីៗ ពីផលប៉ះពាល់សំខាន់ៗ ដែលបណ្តាលមកពីការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធផ្សេងៗ និងហេដ្ឋារចនាសម្ព័ន្ធ រួមទាំងទំនប់វារីអគ្គិសនី ដែលបានផ្លាស់ប្តូររបបរំហូរ ធ្វើឲ្យប៉ះពាល់ដល់ចរាចរកំណកល្បាប់ និងបង្កើនសំណឹកតាមច្រាំង។ ផលប៉ះពាល់ទាំងនេះ បានធ្វើឲ្យមានការធ្លាក់ចុះនូវចំនួនត្រីធម្មជាតិ ការខូចខាតនៃធនធានបរិស្ថាន និងទំនាបលិចទឹក និងការកាត់បន្ថយក្នុងការបំពេញល្បាប់ក្នុងតំបន់ដីសណ្តរ។ ការប្រែប្រួលអាកាសធាតុ ក៏បានបង្កើនភាពធ្ងន់ធ្ងរនៃផលប៉ះពាល់ទាំងនេះបន្ថែមទៀត បង្កឲ្យមានហានិភ័យ និងភាពមិនច្បាស់លាស់កាន់តែច្រើន រួមទាំងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតកាន់តែញឹកញាប់ជាងមុន។

យុទ្ធសាស្ត្រនេះ ដាក់ចេញនូវកម្មវិធីមួយដែលមានវិធានការណ៍ជាអនុសាសន៍នានា ដែលភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់តំបន់អាចអនុវត្តបាន ដើម្បីសម្រេចឲ្យបាននូវអាទិភាពជាយុទ្ធសាស្ត្រនានារបស់ BDS ទាំងតាម BDS នេះផង ទាំងតាមរយៈកម្មវិធី និងគម្រោងផ្ទួចផ្ដើមផ្សេងៗរបស់គេផងដែរ។

MRC នឹងរួមចំណែកយ៉ាងខ្លាំង ដល់អាទិភាពជាយុទ្ធសាស្ត្ររបស់ BDS តាមរយៈផែនការយុទ្ធសាស្ត្ររបស់ខ្លួន (សម្រាប់ឆ្នាំ២០២១-២០២៥) ដែលរួមមានសកម្មភាពចំនួន ៩៥ និងលទ្ធផលរំពឹងទុកចំនួន ៨៦។ គោលដៅថ្មីដែលសំខាន់សម្រាប់កិច្ចការរបស់ MRC រួមមានការវាយតម្លៃដោយបរិសកម្ម និងការកំណត់នូវជម្រើសស្តុកទឹក និងរំហូរទឹកថ្មីៗ និងដែនកម្រិតបរិស្ថានថ្មី និងការផ្ដល់ជាអនុសាសន៍លើគម្រោងវិនិយោគ រួមសម្រាប់អាងទន្លេ ដែលមានពហុប្រយោជន៍សម្រាប់ការគ្រប់គ្រងទឹកជំនន់ ការជួយសង្គ្រោះគ្រោះរាំងស្ងួត សន្តិសុខថាមពល និងការគាំពារបរិស្ថាន។

កិច្ចការដទៃទៀត ក៏នឹងត្រូវអនុវត្ត ដើម្បីធានាថា ផែនការផលិតថាមពលថ្មី បានថ្លឹងថ្លែងនូវប្រភពបង្កើតថាមពលជាច្រើន រួមទាំងសមាហរណកម្មជម្រើសថាមពល និងទឹក និងការប្រើប្រាស់បន្ថែមនៃថាមពលដោយខ្យល់ និងដោយពន្លឺព្រះអាទិត្យ។ យន្តការទាំងនេះ នឹងបង្កើនឲ្យមាននិរន្តភាព ស្របពេលដែលវាឆ្លើយតបទៅនឹងហានិភ័យអាកាសធាតុដែលអាចកើតមាន។

MRC នឹងបន្តស្វែងរកនូវវិធីសម្របសម្រួលផ្សេងៗ សម្រាប់ប្រតិបត្តិការនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធក្នុងអាងទាំងមូល ដើម្បីពង្រឹងអត្ថប្រយោជន៍របស់វា និងកំហិតផលប៉ះពាល់អវិជ្ជមានលើបរិស្ថានរបស់ទន្លេមេ នៃទន្លេមេគង្គ។ គណៈកម្មការនេះ នឹងបន្តការងារជាមួយនឹងភាគីពាក់ព័ន្ធ និងវេទិកាពាក់ព័ន្ធទន្លេមេគង្គនានា ជាពិសេសកិច្ចសហប្រតិបត្តិការស្តីពីទឹកមេគង្គ-ឡានឆាង ដើម្បីធានាឲ្យមានការជូនដំណឹងទាន់ពេលវេលា ជួយឲ្យមានការសម្របសម្រួល និងទ្រទ្រង់ដល់ការបន្សាំទៅនឹងស្ថានភាពទន្លេ ដែលកំពុងប្រែប្រួល។

ក្រោម MRC SP ថ្មីនេះ MRC រំពឹងនឹងធ្វើការវិនិយោគនូវទឹកប្រាក់ជាង ៦០ លានដុល្លារអាមេរិក ក្នុងកំឡុងពេល ៥ឆ្នាំ ដែលធនធានហិរញ្ញវត្ថុប្រមាណ៤០% បានមកពីវិភាគទានពីប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ។ ជាមួយទំហំថវិកាដែលត្រូវការ និងដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះឲ្យបានសម្រេច គេទាមទារឲ្យមានការដឹកនាំប្រកបដោយអនុភាពពីអង្គភាព MRC និង កិច្ចសហប្រតិបត្តិការដ៏សកម្ម និងការគាំទ្រពីដៃគូ និងភាគីពាក់ព័ន្ធ។

MRC SP បន្ទាប់ នឹងត្រូវរៀបចំនៅឆ្នាំ២០២៤ ដើម្បីរួមចំណែកដល់ BDS ឆ្នាំ២០២៦-២០៣០ ដែលនៅសេសសល់។

BDS និង MRC SP កសាងលើការស្រាវជ្រាវដ៏ល្អិតល្អន់អំពីស្ថានភាពអាងទន្លេមេគង្គ រួមទាំងបញ្ហាប្រឈមលើការអភិវឌ្ឍ និងកាលានុវត្តភាពនានា ក៏ដូចជាមេរៀនដែលបានទទួលពីយុទ្ធសាស្ត្រមុនៗ និងការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយនឹងប្រទេសមេគង្គទាំង៦ ដៃគូអភិវឌ្ឍន៍ រដ្ឋាភិបាលថ្នាក់តំបន់ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីតាមស្ថាប័នផ្សេងទៀត។

ចាប់តាំងពីបានបង្កើតនៅឆ្នាំ១៩៩៥ មក MRC បានរៀបចំ MRC SP ចំនួន៥ និង BDS ចំនួន៣ ដែលសំណៅនីមួយៗមានរយៈពេល ៥ឆ្នាំ។ ការផ្លាស់ប្តូររយៈពេល BDS ទៅ ១០ឆ្នាំ ត្រូវបានជំរុញដោយភាពចាំបាច់ក្នុងការបន្សាំវាទៅនឹង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងតម្រូវការអភិវឌ្ឍន៍ដោយចីរភាពនៃអាងទន្លេ និងបញ្ហាសន្តិសុខទឹក ដែលត្រឹមតែអាចដោះស្រាយបាននៅកម្រិតអាងទន្លេ តាមរយៈកិច្ចសហប្រតិបត្តិការរវាងប្រទេសតាមអាងទន្លេទាំង៦ និងសហគមន៍ទាំងអស់ ដែលរស់នៅក្នុងតំបន់ទន្លេមេគង្គ។

BDS អាចនឹងសម្រេចបាន បើភាគីពាក់ព័ន្ធទាំងអស់ ធ្វើការរួមគ្នាដើម្បីអាងទន្លេមេគង្គតែមួយ ដែលមានភាពរីកចម្រើនផ្នែកសេដ្ឋកិច្ច យុត្តិធម៌សង្គម បរិស្ថានល្អ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

កំណត់សម្គាល់សម្រាប់និពន្ធនាយក៖

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជាជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីអភិវឌ្ឍន៍តំបន់នេះប្រកបដោយចីរភាព។

ចប់

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក មាស សុកក្រ្ត មន្ត្រីទំនាក់ទំនងសម្រាប់អ្នកសារព័ត៌មាន
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរសព្ទដៃ៖ +856-20-77779168

###